# ច្បាប់

# ស្តីពី

# សញ្ជាតិ

# ROYAL DECREE
# ON
# KHMER NATIONALITY

SOURCE: COUNCIL OF JURISTS

WWW.KHMERKROMNGO.ORG

១០៥៣

# ព្រះរាជក្រម

**ROYAL DECREE ON KHMER NATIONALITY**

នស/រកម/១០៩៦/៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

[illegible]
ចូល លេខ..៧៤...
ថ្ងៃទី..០០..ខែ..ម៉ោង..១០:..
បញ្ជូនទៅ...

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

Source: Council of Jurists

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី សញ្ជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ សីហា ឆ្នាំ១៩៩៦ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

WWW.KHMERKROMNGO.ORG

## ជំពូកទី ១

### បទបញ្ញត្តិទូទៅ

ROYAL DECREE
ON
KHMER NATIONALITY

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់សញ្ជាតិខ្មែរ ចំពោះជនដែលបំពេញលក្ខខណ្ឌនៃច្បាប់នេះ ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ។

**មាត្រា ២.-**

ជនណាមានសញ្ជាតិខ្មែរ ជាប្រជាពលរដ្ឋខ្មែរ ។

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេសឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

**មាត្រា ៣.-**

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស ៖

១-ត្រូវបានរដ្ឋការពារតាមគ្រប់មធ្យោបាយការទូត

២-មិនអាចបាត់បង់សញ្ជាតិដោយឯកឯង ។

## ជំពូកទី ២

### សញ្ជាតិខ្មែរតាមកំណើត

**មាត្រា ៤.-**

១-ត្រូវបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ ៖

-កូនមានខាន់ស្លាដែលកើតមកពីឪពុកឬម្ដាយមានសញ្ជាតិខ្មែរ ឬ

-កូនឥតខាន់ស្លាដែលកើតមកពីឪពុកឬម្ដាយមានសញ្ជាតិខ្មែរទទួលស្គាល់ ឬ

-កូនដែលឪពុក ម្ដាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុកឬម្ដាយដែលមានសញ្ជាតិខ្មែរ ។

២-ត្រូវបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖

ក-កូនដែលកើតពីឪពុកនិងម្ដាយបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-កូនដែលកើតពីឪពុក ម្ដាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

## ជំពូកទី ៣

## សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

មាត្រា ៥.-

ស្ត្រីឬបុរសបរទេសដែលយកប្តីឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រីឬបុរសនោះរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ។

បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

មាត្រា ៦.-

ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសទេ ។

## ជំពូកទី ៤

## សញ្ជាតូបនីយកម្ម

មាត្រា ៧.-

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។

សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ នោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលបានតាមអំណាចឆន្ទានុសិទ្ធិ ។

មាត្រា ៨.-

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

១- មានលិខិតបញ្ជាក់ថាមានគំនិតមារយាទនិងសីលធម៌ល្អ ដែលចេញឱ្យដោយមេឃុំឬចៅសង្កាត់នៃទីលំនៅរបស់ខ្លួន

២- មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ

៣- មានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ជំនួនប្រាំពីរឆ្នាំ ដោយគិតពីថ្ងៃដែលបានទទួលប័ណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍

៤- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំសញ្ជាតូបនីយកម្ម

៥- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបញ្ជាក់ឱ្យឃើញច្បាស់ថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលយកនូវទំនៀមទម្លាប់និងប្រពៃណីល្អរបស់ខ្មែរ

៦- មានបញ្ញានិងកាយសម្បទាដែលមិនឱ្យមានគ្រោះថ្នាក់ឬឱ្យមានបន្ទុកដល់ជាតិ ។

មាត្រា ៩.-

ចំពោះជនបរទេសណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួនប្រាំពីរឆ្នាំ ដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះ ត្រូវបន្ថយមកនៅបីឆ្នាំវិញ ។

មាត្រា ១០.-

ចំពោះជនបរទេសណាដែលបានទទួលលិខិតអនុញ្ញាតឱ្យវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយដែលបានអនុវត្តគំរោងជាក់ស្តែងចំណាយទុនចំនួនចាប់ពីមួយពាន់ពីររយហាសិបលានរៀល ( ១.២៥០.០០០.០០០រៀល ) ឡើងទៅ រយៈពេលស្នាក់នៅដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះត្រូវបានលើកលែង ។

មាត្រា ១១.-

ចំពោះជនបរទេសណាដែលពុំមានលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តែបានទទួលការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ហើយដែលបានចំណាយទុនវិនិយោគចាប់ពីចំនួនមួយពាន់ពីររយហាសិបលានរៀល ( ១.២៥០.០០០.០០០រៀល ) ឡើងទៅ រយៈពេលស្នាក់នៅដែលមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះត្រូវបានលើកលែង ។

មាត្រា ១២.-

ជនបរទេសណាដែលបានធ្វើអំណោយជាប្រាក់ដល់ថវិកាជាតិចាប់ពីមួយពាន់លានរៀល ( ១.០០០.០០០.០០០រៀល ) ឡើងទៅ សំរាប់ជាផលប្រយោជន៍ដល់ការស្តារនិងកសាងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចធ្វើពាក្យសុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុចទី ១,ទី ២, ទី ៤ និង ទី ៦ មាត្រា ៨ នៃច្បាប់នេះ ។

មាត្រា ១៣.-

ជនបរទេសដែលបានបង្ហាញនូវភស្តុតាងថាខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា អាចធ្វើពាក្យសុំចូលសញ្ជាតិខ្មែរបានដោយពុំចាំបាច់បំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះ ។

មាត្រា ១៤.-

ជនបរទេសដែលមានសហព័ទ្ធឬកូនដែលមានអាយុតិចជាង ១៨ឆ្នាំ ដែលមានបំណងសុំសញ្ជាតិខ្មែរ អាចសុំសញ្ជាតិខ្មែរជាក្រុមគ្រួសារ ។

មាត្រា ១៥.-

ជនបរទេសអាចសុំប្តូរផ្លាស់ឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ឈ្មោះនោះក្នុងពាក្យសុំសញ្ជាតិខ្មែររបស់ខ្លួន ។

មាត្រា ១៦.-

សញ្ជាតិខ្មែរដែលផ្តល់ចំពោះជនណាម្នាក់ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

បែបបទនិងនីតិវិធីនៃការសុំសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAL DECREE
ON
KHMER NATIONALITY

មាត្រា ១៧.-

ជនដែលបានអនុញ្ញាតឱ្យចូលជាសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះមានចែងនៅក្នុងអនុក្រឹត្យ ។

ROYAL DECREE
ON
KHMER NATIONALITY

## ជំពូកទី ៥

## ការបាត់សញ្ជាតិខ្មែរ

មាត្រា ១៨.-

ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ឆ្នាំយ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត និងដោយគ្មានការបង្ខិតបង្ខំ ។

នីតិវិធីនិងល័ក្ខខ័ណ្ឌនៃការសុំលះបង់សញ្ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

មាត្រា ១៩.-

មានតែប្រជាពលរដ្ឋខ្មែរទេ ទើបមានសិទ្ធិទទួលនិងកាន់កាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២០.-

ជនបរទេសណា ដែលកាន់កាប់និងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

មាត្រា ២១.-

ជនណាដែលក្លែង ធ្វើការកោស លុប សរសេរត្រួតឬឱ្យគេជំនួសរូបថតឬសរសេរឈ្មោះក្លែងក្លាយ នៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ឬមួយប្រើប្រាស់ឯកសារទាំងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

មាត្រា ២២.-

មន្ត្រី ភ្នាក់ងាររាជការឬជនណាដែលសមគំនិត ជួយលាក់លៀម ឬផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនឱ្យជនណាម្នាក់ដែលគ្មានសញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដូចគ្នានឹងជនដែលកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនដោយខុសច្បាប់ ដូចមានចែងក្នុងមាត្រា ២០និងមាត្រា ២១ នៃច្បាប់នេះ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦

ROYAL DECREE
ON
KHMER NATIONALITY

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស_ខេង យូ ហុកគ្រី